មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០២-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៥០ ស្តីពីការតែងតាំងលោក **ស្រី សុធា** ជា ឧកញ៉ា ២៤៥៤

០៥-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៥៨ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **គីម ម្យុង អ៊ីល** (KIM MYUNG IL) ជនជាតិកូរ៉េ កើតនៅ Kyung Sngbuk-dO សាធារណរដ្ឋកូរ៉េ ២៤៥៥

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៧៣ ស្តីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម **ឆាន់ សាផាន** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ២៤៥៦

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៧៤ ស្តីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម **ខិក វិជ័យ** នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ២៤៥៧

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៧៥ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **កាង សាង ហូ** (KANG SANG HO) ជនជាតិកូរ៉េ កើតនៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ២៤៥៨

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៧៦ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចំនួន ០២ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ២៤៥៩

១៣-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៧៧ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ២៤៦០

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

២៤-៤-២០០៦ -អនុក្រឹត្យលេខ ៣៥ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិ គ្រប់គ្រងការប្រែប្រួលអាកាសធាតុ ២៤៦១

២៤-៤-២០០៦ -អនុក្រឹត្យលេខ ២៦៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៤៦៦

២៤-៤-២០០៦ -អនុក្រឹត្យលេខ ២៦៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៤៦៧

២៥-៤-២០០៦ -អនុក្រឹត្យលេខ ២៦៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៤៦៨

២៥-៤-២០០៦ -អនុក្រឹត្យលេខ ២៦៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៤៦៩

២៥-៤-២០០៦ -អនុក្រឹត្យលេខ ២៦៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៤៧០

III-ភាពរាជបណ្ណាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៧-៤-២០០៦ -ប្រកាសលេខ ២៨០សហវ.ហម ស្តីពីការកែសំរួលសមាសភាពក្រុមការងារជំនាញវិមជ្ឈការ និងវិសហមជ្ឈការអមគណៈកម្មាធិការកំណែទំរង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ២៤៧១

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២១-៤-២០០៦ -ប្រកាសលេខ ៤៤០ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **វីន សូល ហ្គាមេន (ខេមបូឌា)** បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " វីន សូល ហ្គាមេន (ខេមបូឌា)" ២៤៧៥

២១-៤-២០០៦ -ប្រកាសលេខ ៤៤១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ឃែនធើរេន អីភែ វិល (ខេមបូឌា)** បង្កើតសាខារោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមាន ឈ្មោះ ថា " ឃែនធើរេន អីភែ វិល (ខេមបូឌា)" ២៤៧៧

២៥-៤-២០០៦ -ប្រកាសលេខ ៤៩១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ជេនើរេសិន អ៊ិនធើណេសិនណល** បង្កើតសាខារោងចក្រ " ស្បែកជើង " ដែលមានឈ្មោះថា "ជេនើរេសិន អ៊ិនធើណេសិនណល" ២៤៧៩

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

១៣-៤-២០០៦ -ប្រកាសលេខ ១៣៧ ប្រក.កសក ស្តីពីការលុបចោលរោងចក្រអារ-កែច្នៃឈើ ជាសាខាក្រុមហ៊ុនព្រៃសម្បទានក្នុងទូទាំងប្រទេស ២៤៨១

៤-ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

១៥-៣-២០០៦ -លិខិតលេខ ៧៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាល់ត្រាហ្គោល-អេស៊ា** ២៤៨៣

១៥-៣-២០០៦ -លិខិតលេខ ៧៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វែល ឃែរ ហ្វាម៉ា** ២៤៨៥

១៥-៣-២០០៦ -លិខិតលេខ ៧៦២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផេឡាញ** ២៤៨៧

១៦-៣-២០០៦ -លិខិតលេខ ៧៦៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សហប្រតិបត្តិការ យូរ & អេច គ្រុប** ២៤៨៩

១៦-៣-២០០៦ -លិខិតលេខ ៧៦៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វាញ ហារីស ខនសាល់ធេន** ២៤៩១

១៦-៣-២០០៦ -លិខិតលេខ ៧៦៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ីន សំណាង អេតិចឡាន់** ២៤៩៣

១៦-៣-២០០៦ -លិខិតលេខ ៧៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីណូស្ទីល (ខេមបូឌា) ខូ អិលធីឌី** ២៤៩៥

១៦-៣-២០០៦ -លិខិតលេខ ៧៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី.ធី.ស៊ី គ្រុប** ២៤៩៧

១៦-៣-២០០៦ -លិខិតលេខ ៧៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សារី ផេតើរ ខូ អិលធីឌី** ២៤៩៩

១៦-៣-២០០៦ -លិខិតលេខ ៧៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ី_ដាតា ត្រេឌីង** ២៥០១

១៦-៣-២០០៦ -លិខិតលេខ ៧៧៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្រីវត្ត អ៊ិនធើណេសិនណាល ត្រាវែល & ធួរ (អេស អាយ ធី ធី)** ២៥០៣

១៦-៣-២០០៦ -លិខិតលេខ ៧៨៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **កោះសេះ រីហ្សត** ២៥០៥

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៥០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោក ស្រី សុធា

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពាក.០៦០៤.១៥៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ៦ ខែមេសាឆ្នាំ ២០០៦

លេខៈ ១៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី៧៥ ខែមេសាឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ម៉ាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៥៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក គីម ម្យុង អ៊ីល (KIM MYUNG IL)) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៥៨ នៅ Kyung Sngbuk-d0 សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

លេខៈ ១៥៧. ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាវ តាន់

៣រល.០៦០៤.១៦៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០០៦

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម **ឆាន់ សាផាន**

នូវ

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.០៦០៤.១៧២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦

លេខ: ១៨៣. ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៧៤

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

លោក ខិត វិជ័យ

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

ពាក. ០៦០៤. ១៩៣

លេខ: ៣៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៦
រដ្ឋលេខាធិការរាជរដ្ឋាភិបាល
(ហត្ថលេខា)
ស៊ុណាំ តាន់

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០០៦

ឃ

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **គាង សាង ហូ** (KANG SANG HO) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៤១ នៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤.០៤០៤.១៧៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦

លេខៈ ១៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានទទួលការប្រោសប្រទាននូវ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចំនួន ០២ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើ ជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

១- លោក កែន សត្ថា
២- លោក មុត មន

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៣.០៦០៤.១៩៥

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦

លេខ: ១៧៨ ច.ល
ចំលងចំលងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
សៅរ៉ាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានទទួលការប្រោសប្រទាននូវ គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ អស្សឫទ្ធិ ជូនមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើ ជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

១- លោក **ញ៉ា វ៉ាងចាន់**
២- លោក **ឡាច ស៊ីមអួន**
៣- លោក **ស្វាយ សំអ៊ាង**

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរ.ល. ០៦០៤.១៧៦

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦

លេខ: ៣៧៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាឌី តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣៥...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៥ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៦ ។

សម្រេច

មាត្រា ១ ..

បង្កើត **គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ** ហៅកាត់ថា **គ.ជ.គ.ប.អ** ជាភាសាអង់គ្លេសហៅថា National Climate Change Committee (NCCC) ក្នុងទិសដៅរៀបចំ សម្របសម្រួល និងតាមដានពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា របស់រាជរដ្ឋាភិបាលសំដៅឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុក្នុងប្រទេស រួមចំណែកការពារបរិស្ថាន និងធនធានធម្មជាតិ ដើម្បីឱ្យបានដឹងជាមុន និងទប់ស្កាត់ការប្រែប្រួលអាកាសធាតុបណ្តាលមកពីមនុស្ស ដែលអាចបង្កឥទ្ធិពលអវិជ្ជមានចំពោះសុខុមាលភាពនៃមនុស្សជាតិ ។

មាត្រា ២ ..

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ជាយន្តការអន្តរក្រសួង មានចរិតលក្ខណៈអន្តរវិស័យ និងពហុជំនាញ ដែលមានសមាសភាពដូចខាងក្រោម ៖

១.	រដ្ឋមន្ត្រីក្រសួងបរិស្ថាន		ប្រធាន
២.	រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	មួយ (០១) រូប	អនុប្រធាន
៣.	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	មួយ (០១) រូប	អនុប្រធាន
៤.	រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	មួយ (០១) រូប	អនុប្រធាន
៥.	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	មួយ (០១) រូប	សមាជិក
៦.	អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	មួយ (០១) រូប	សមាជិក
៧.	អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ	មួយ (០១) រូប	សមាជិក
៨.	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	មួយ (០១) រូប	សមាជិក
៩.	អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន	មួយ (០១) រូប	សមាជិក
១០.	អនុរដ្ឋលេខាធិការក្រសួងផែនការ	មួយ (០១) រូប	សមាជិក
១១.	អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	មួយ (០១) រូប	សមាជិក
១២.	អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	មួយ (០១) រូប	សមាជិក
១៣.	អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល	មួយ (០១) រូប	សមាជិក
១៤.	អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	មួយ (០១) រូប	សមាជិក

១៥. អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	មួយ (០១) រូប	សមាជិក
១៦. អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន	មួយ (០១) រូប	សមាជិក
១៧. អគ្គលេខាធិការរងគណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ	មួយ (០១) រូប	សមាជិក
១៨. អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	មួយ (០១) រូប	សមាជិក
១៩. អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា	មួយ (០១) រូប	សមាជិក

មាត្រា ៣ .-

គ.ជ.គ.ប.អ មានតួនាទី និងភារកិច្ច សម្របសម្រួល និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងទិសដៅដូចតទៅ ៖

- រៀបចំសេចក្តីព្រាងគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ស្តីពីការប្រែប្រួលអាកាសធាតុ ដោយរួមទាំងផែនការជាតិកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងផែនការជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងទូលំទូលាយ ពីភាគីពាក់ព័ន្ធទាំងអស់ នៅក្នុងការរៀបចំ និងក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ស្តីពីការប្រែប្រួលអាកាសធាតុ ឱ្យមានប្រសិទ្ធភាព ឆ្លើយតបទៅនឹងបណ្តាអាទិភាព និងគោលដៅអភិវឌ្ឍន៍របស់ជាតិ
- ជំរុញ និងលើកទឹកចិត្តការដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ដែលពាក់ព័ន្ធ
- កៀរគរធនធានដែលចាំបាច់ ពិសេសការទាក់ទាញជំនួយឥតសំណង សម្រាប់អនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ស្តីពីការប្រែប្រួលអាកាសធាតុ
- ជំរុញ និងលើកទឹកចិត្តការផ្ទេរបច្ចេកវិជ្ជាថាមពលសមស្រប និងថាមពលកកើតឡើងវិញ ការអភិរក្ស និងការកែលំអអាងផ្ទុកកាបូន
- កំណត់គោលជំហរ និងយុទ្ធសាស្ត្រជាតិ សម្រាប់ចូលរួមក្នុងកិច្ចចរចា នៃកិច្ចប្រជុំអន្តរជាតិនានា ស្តីពីការប្រែប្រួលអាកាសធាតុ
- ពិនិត្យ និងអនុម័តលើរបាយការណ៍ផ្លូវការនានារបស់ជាតិ ដែលតម្រូវឱ្យរៀបចំ នៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- សម្របសម្រួលសកម្មភាពនានា ដែលពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ពិធីសារនានាក្រោមអនុសញ្ញានេះ និងកិច្ចព្រមព្រៀងអន្តរជាតិនានា ស្តីពីការប្រែប្រួលអាកាសធាតុ ដែលភាគីកម្ពុជាបានចូលជាសមាជិករួចហើយ

- ទទួលបន្ទុកគ្រប់គ្រង និងសម្របសម្រួលការងារយន្តការអភិវឌ្ឍន៍ស្អាតនៃពិធីសារក្យូតូ នៅកម្ពុជា
- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ ការអនុវត្តអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ និងដំណើរការចរចាថ្នាក់អន្តរជាតិ
- ជំរុញការអប់រំ ការយល់ដឹង ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយព័ត៌មានដល់សាធារណជនទូទៅ ស្តីពីការប្រែប្រួលអាកាសធាតុ
- ចូលរួមក្នុងកិច្ចប្រជុំ សន្និសីទ និងសិក្ខាសាលាថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ស្តីពីបញ្ហាដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ
- សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តបណ្តាគម្រោង កម្មវិធី និងសកម្មភាពស្រាវជ្រាវនានា ដែលពាក់ព័ន្ធនឹងបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា
- ពិនិត្យ និងអនុម័តលើផែនការការងារ និងរបាយការណ៍នានារបស់ **ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ** ហៅកាត់ថា **ក.ប.ក.ប.អ** (Climate Change Technical Team: CCTT) ដែលនឹងត្រូវបង្កើតឡើង អនុលោមតាមមាត្រា ៤ នៃអនុក្រឹត្យនេះ
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ។

មាត្រា ៤ .-

គ.ជ.គ.ប.អ ត្រូវរៀបចំបង្កើត **ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ** (**ក.ប.ក.ប.អ**) ។ **ក.ប.ក.ប.អ** មានភារកិច្ចទទួលខុសត្រូវលើការងារបច្ចេកទេស និងលើកមតិយោបល់ ដែលទាក់ទងទៅនឹងការងារប្រែប្រួលអាកាសធាតុនៅកម្ពុជា ជូនដល់ **គ.ជ.គ.ប.អ** ក្នុងការបំពេញភារកិច្ច ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។

ក.ប.ក.ប.អ មានមន្ត្រីជំនាញ ជាតំណាងមកពីបណ្តាក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលមានបេសកកម្មពាក់ព័ន្ធនឹងការងារប្រែប្រួលអាកាសធាតុ និងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។ **ក.ប.ក.ប.អ** មានទីតាំងនៅក្រសួងបរិស្ថាន ។

មាត្រា ៥ .-

សមាជិក **គ.ជ.គ.ប.អ** ទាំងអស់ ត្រូវចូលរួមប្រជុំឱ្យបានទៀងទាត់ តាមការកោះអញ្ជើញរបស់ប្រធាន **គ.ជ.គ.ប.អ** ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមួយរូបត្រូវដឹកនាំការប្រជុំ តាមការប្រគល់សិទ្ធិរបស់ប្រធាន ។ អង្គការជាតិ អង្គការអន្តរជាតិដែលពាក់ព័ន្ធ អាចចូលរួមប្រជុំបាន តាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានទទួលសិទ្ធិ ។

គ.ជ.គ.ប.អ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ។

មាត្រា ៦ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីនៃក្រសួងនិងប្រធាននៃស្ថាប័នដែលពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមសមត្ថកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៨រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ ដូចជា ព្រះវិហារ កុដិ ឧបដ្ឋានសាលា ស្រះទឹក អាងទឹក និងម៉ាស៊ីនភ្លើង នៅវត្តបទុមារាម ក្នុងឃុំគោករវៀង ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដូចមានព្រះនាម និងនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**មហាសុវណ្ណ**	**សុវណ្ណរាត**	គង់នៅប្រទេសសិង្ហបុរី	បច្ច័យចំនួន ១០៨.៣៧៨ ដុល្លារ
២-លោក	**ឈួ**	**ហ្សុមីន**	នៅប្រទេសសិង្ហបុរី	ថវិកាចំនួន ៤៩.៩០០ ដុល្លារ
៣-លោកស្រី	**សាន**	**ជូរ**	នៅក្រុងភ្នំពេញ	ថវិកាចំនួន ១២.៦៧៤ ដុល្លារ
៤-លោកស្រី	**យ៉ែម**	**សុគន្ធា**	នៅក្រុងភ្នំពេញ	ថវិកាចំនួន ១២.៥០០ ដុល្លារ

ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :

១-ព្រះតេជគុណ	**អ៊ិន**	**ថៃ**	គង់នៅវត្តបទុមារាម	បច្ច័យចំនួន ២.១៨២ ដុល្លារ
២-លោក	**ប៉ែន**	**សុជាតិ**	នៅក្រុងព្រះសីហនុ	ថវិកាចំនួន ៣.៤២៥ ដុល្លារ
៣-លោក	**ទិត**	**ផេន**	នៅក្រុងភ្នំពេញ	ថវិកាចំនួន ៣.៤២១ ដុល្លារ
៤-លោកស្រី	**គឹម**	**ស្រួយ**	នៅក្រុងភ្នំពេញ	ថវិកាចំនួន ៣.១៥០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤២៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

ខ្សែរ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ ជូនមន្ត្រីរាជការ និងជូនសប្បុរសជន ចំនួន០៣រូប ដែលមានស្នាព្រះហស្ត និងស្នាដៃល្អ ក្នុងការជួយកសាង និងអភិវឌ្ឍន៍ ព្រះពុទ្ធសាសនា និងសង្គម ដូចមានព្រះនាម និងនាមខាងក្រោម :-

ក_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ព្រះភិក្ខុ **ហ៊ឹម សុធាវី** (សីលសំវរត្ថេរ) ព្រះចៅអធិការវត្តមេសរារាម ឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។
២-លោក **ស្រី គានឿន** នាយកមន្ទីរធម្មការ និងសាសនា ខេត្តកំពង់ចាម

ខ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

-ឧបាសក **អ៊ិត គ្រួយ** នៅភូមិវាលវង់ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញៈថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៩៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
៙
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តសង្កែសាទប ឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដូចមាន រាយព្រះនាមនិងនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

-ព្រះតេជគុណ **សុភារៈ** ព្រះអនុគណស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ និងជាព្រះចៅអធិការ វត្តភ្នំចាស់

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-ព្រះតេជគុណ **ឌិត្ស ជន** ព្រះធម្មធរស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ និងជាព្រះចៅអធិការ វត្តតាលូតគីរីមានជ័យ
២-ព្រះតេជគុណ **នួន ចន្ទួន** លេខាគណស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ និងជាព្រះចៅអធិការវត្តសង្កែសាទប
៣-លោកឧត្តមសេនីយ៍ត្រី **មិន នឹម** មេបញ្ជាការរង យោធភូមិភាគទី៣
៤-លោកស្រី **យឹម គីរី** សប្បុរសជន
៥-លោក **លី អាងស៊ុយ** សប្បុរសជន
៦-លោកស្រី **ឡោ ប៊ុណ្ណាត** សប្បុរសជន

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥២៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន១០រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវត្តព្រះធាតុ ឃុំរលូស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**ឡុង**	**ពុទ្ធិសំក**	បច្ច័យ ចំនួន ២៨.៩៥០ ដុល្លារ
២-ព្រះតេជគុណ	**វ៉ែន**	**សារឿន**	បច្ច័យ ចំនួន ១៣.៦០០ ដុល្លារ
៣-ឧបាសិកា	**ជាង**	**ភាគតាង**	ថវិកា ចំនួន ១២.១៥០ ដុល្លារ
៤-លោក	**សាំ**	**សាខន**	ថវិកា ចំនួន ១០.១៥០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-លោកស្រី	**ម៉ែន**	**ម៉ៅ**	ថវិកា ចំនួន ៥.៧៣០ ដុល្លារ
២-ឧបាសិកា	**ង៉ូវ**	**មួយ**	ថវិកា ចំនួន ៥.៧០០ ដុល្លារ
៣-ឧបាសិកា	**តិ៍ម**	**តន់**	ថវិកា ចំនួន ៥.៥០០ ដុល្លារ
៤-លោក	**យូ**	**ចន**	ថវិកា ចំនួន ៥.៤០០ ដុល្លារ
៥-លោកស្រី	**តេង**	**គីមអ៊ីវ**	ថវិកា ចំនួន ៥.៧០០ ដុល្លារ
៦-លោកអាចារ្យ	**យី**	**សារិន**	ថវិកា ចំនួន ៥.៣០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៦៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៨រូប ដែលបាន បរិច្ចាគធនធានជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តភ្នំមាស ឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមាន រាយព្រះនាមនិងនាមខាងក្រោម :-

១-ព្រះតេជគុណ	**សុខ និល**	ព្រះចៅអធិការវត្តភ្នំមាស
២-ឧបាសក	**ភាំង ណារ៉ះអោខ**	សប្បុរសជន
៣-ឧបាសិកា	**ហោ លាន**	សប្បុរសជន
៤- លោក	**នុត សោភ័ណ្ឌ**	សប្បុរសជន
៥-លោក	**ថៅ គឿន**	សប្បុរសជន
៦-លោក	**យន់ ប៊ុនឡេង**	សប្បុរសជន
៧-លោក	**ប៉ៀង ឆាលី**	សប្បុរសជន
៨-លោក	**ម៉ៅ ម៉ុន**	ប្រធានគណៈកម្មការវត្ត

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧២០ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មេសា ឆ្នាំ ២០០៦

ប្រកាស

ស្តីពី

ការកែសំរួលសមាសភាពក្រុមការងារជំនាញទីមជ្ឈការ និងវិសហមជ្ឈការ អមគណៈកម្មាធិការកំណែទំរង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៧04/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២00៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៧04/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២00៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ 0២/នស/៩៤ ចុះថ្ងៃទី ២0 ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/0១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ 0៤ អនក្រ.បក ចុះថ្ងៃទី ២0 ខែ មករា ឆ្នាំ ២000 ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បកចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២00៤ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញប្រកាសលេខ ២១៨ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីការបង្កើតគណៈកម្មាធិការកែទំរង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតំរូវការជាបន្ទាន់ នៃកំណែទំរង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្នុងការសម្របសម្រួលកម្មវិធីកំណែទំរង់នេះ ជាមួយកម្មវិធីកំណែទំរង់វិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១: កែសំរួលសមាសភាព "ក្រុមការងារជំនាញវិមជ្ឈការ និង វិសហមជ្ឈការ" នៅអមគណៈកម្មាធិការកំណែទំរង់ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម:

១. **ឯកឧត្តម ជូ គឹមឡេង**	អគ្គលេខាធិការរង ក្រសួង ស.ហ.វ	ប្រធាន
២. **លោក ទូច ឡេង**	ប្រធាននាយកដ្ឋាន ហិរញ្ញកិច្ច	អនុប្រធាន
៣. **លោក លីវ ប៊ុនហៃ**	ប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុមូលដ្ឋាន	អនុប្រធាន
៤. **លោក រស់ សីលវ៉ា**	ប្រធាននាយកដ្ឋាន គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ	សមាជិកអចិន្ត្រៃយ៍
៥. **លោក ម៉ម ប៊ុន**	អនុប្រធានទី១ នាយកដ្ឋានថវិកា	សមាជិក
៦. **លោក ប៊ូ វង្សសុខា**	អនុប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុមូលដ្ឋាន	សមាជិក
៧. **លោក ឈឹម សារ៉េត**	អនុប្រធានរតនាគារជាតិ	សមាជិក
៨. **លោក ចាន់ ស៊ុំ**	អនុប្រធាននាយកដ្ឋាន ពន្ធដារ	សមាជិក
៩. **លោក សាន ផាន់នី**	អនុប្រធាននាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋ	សមាជិក
១០. **លោក ម៉ៅ បុញ្ញខេត្ត**	ប្រធានការិយាល័យទី៣ ចំណូលមិនមែនសារពើពន្ធ	សមាជិក
១១. **លោក ហ៊ូ គុណវុឌ្ឍន៏**	ប្រធានការិយាល័យគោលនយោបាយ និង សរុប នៃនាយកដ្ឋាន វិនិយោគ និងសហប្រតិបត្តិការ	សមាជិក

ប្រការ ២: "ក្រុមការងារជំនាញវិមជ្ឈការ និង វិសហមជ្ឈការ" នៃគណៈកម្មាធិការកំណែទំរង់មានតួនាទី និង ភារកិច្ចដូចតទៅ :

- ដើរតួនាទី ជាសេនាធិការបច្ចេកទេស របស់គណៈកម្មាធិការកំណែទំរង់នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការសម្របសម្រួលកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីវិមជ្ឈការ និង វិសហមជ្ឈការហិរញ្ញវត្ថុ ជាមួយនឹងការងារកំណែទំរង់ និង គោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា ។
- សម្របសម្រួលកិច្ចសហប្រត្តិបត្តិការរវាងនាយកដ្ឋានផ្សេងៗ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលធ្វើការពាក់ព័ន្ធនឹងការងារវិមជ្ឈការ និង វិសហមជ្ឈការ ជំនួសមុខអោយគណៈកម្មាធិការកំណែទំរង់ ។

- ដោយឡែកត្រូវផ្ដល់ការណែនាំ និង សម្របសម្រួលក្រុមការងារជំនាញផ្សេងៗ ដែលបានបង្កើតឡើងនៅក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីដោះស្រាយបញ្ហាជាក់ស្ដែងនានា ពាក់ព័ន្ធនឹងវិមជ្ឈការ និង វិសហមជ្ឈការ (ក្នុងនោះ រួមមាន : (១).ក្រុមការងាររបស់មូលនិធិឃុំ/សង្កាត់ ដែលបានបង្កើតឡើងតាមប្រកាសលេខ ១៥២ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ (២). មន្ត្រីតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលអមដោយមន្ត្រីមួយចំនួនតាមចំណារ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០៤ របស់ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លើលិខិតលេខ ៨១៧/០៤ ក.អ.ក/គ.ជ.ន ស្ដីពីសំណើចាត់តាំងមន្ត្រីជាន់ខ្ពស់សំរាប់ចូលរួមរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រស្ដីពីវិមជ្ឈការ និងវិសហមជ្ឈការ និង (៣).ក្រុមការងារជំនាញផ្សេងៗទៀត ដែលអាចនឹងត្រូវបង្កើតឡើង នាក់ឡុងពេលអនុវត្តកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈព្រមទាំងកំណែទំរង់ និងគោលនយោបាយនានាស្ដីពីវិមជ្ឈការ និង វិសហមជ្ឈការ ។
- ធ្វើជា "ចំណុចប្រមូលផ្ដុំ" របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់សម្របសម្រួលការងារជាមួយស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាល ទាក់ទងនឹងការអភិវឌ្ឍន៍ និង ការអនុវត្តន៍នូវគោលនយោបាយ យុទ្ធសាស្ត្រ និង ផែនការវិមជ្ឈការ និង វិសហមជ្ឈការ ជំនូសមុខអោយគណៈកម្មាធិការកំណែទំរង់ ។
- ធ្វើជា "ចំនុចប្រមូលផ្ដុំ" របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងការសម្របសម្រួលជាមួយអ្នកផ្ដល់ជំនួយលើការផ្ដល់ជំនួយសំរាប់ការងារវិមជ្ឈការ និង វិសហមជ្ឈការ នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីផ្សេងៗទៀតជំនួសមុខឱ្យគណៈកម្មាធិការកំណែទំរង់ ។
- លើកឡើងនូវបញ្ហាទាក់ទងនឹងវិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីដាក់ជូនគណៈកម្មាធិការកំណែទំរង់ធ្វើការពិចារណា សំរេចចិត្ត និង ផ្ដល់អនុសាសន៍ ជូនដល់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- ចូលរួមក្នុងការរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ក្របខ័ណ្ឌចំណូល-ចំណាយថវិកាជាតិ និងការរៀបចំថវិកាប្រចាំឆ្នាំ ជាពិសេស ថវិកាខេត្ត/ក្រុង និង ថវិកាឃុំ/សង្កាត់ ។

ប្រការ ៣: "ក្រុមការងារជំនាញវិមជ្ឈការ និង វិសហមជ្ឈការ" អមគណៈកម្មាធិការកំណែទំរង់នឹងត្រូវកោះប្រជុំជាទៀងទាត់ តាមការអញ្ជើញរបស់ប្រធានក្រុមការងារ ស្របតាមតំរូវការក្នុងការសម្របសម្រួលការងាររបស់ក្រុមឯកទេសផ្សេងៗ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធិភាព និង រាយការណ៍ជូនជាប្រចាំ ដល់គណៈកម្មាធិការកំណែទំរង់លើបញ្ហាទាក់ទងទៅនឹងវិមជ្ឈការ និង វិសហមជ្ឈការ ស្របនឹងដំណើរការវិវឌ្ឍន៍នៃកម្មវិធីកំណែទំរង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ប្រការ ៤: ប្រធាន "ក្រុមការងារជំនាញវិមជ្ឈការ និង វិសហមជ្ឈការ" នៃគណៈកម្មាធិការកំណែទំរង់អាចអញ្ជើញប្រធាននាយកដ្ឋាន ជំនាញការ និង ទីប្រឹក្សាបច្ចេកទេសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមិនមែនជាសមាជិក "ក្រុមការងារជំនាញវិមជ្ឈការ និង វិសហមជ្ឈការ" នៃគណៈកម្មាធិការកំណែទំរង់ឱ្យចូលរួមប្រជុំតាមតំរូវការជាក់ស្ដែង ។

ប្រការ ៥: ប្រសិនបើសមាជិកនៃ "ក្រុមការងារជំនាញវិមជ្ឈការ និង វិសហមជ្ឈការ " អមគណៈកម្មាធិការកំណែទំរង់ដែលជាប្រធាននាយកដ្ឋានមិនអាចមកចូលរួមប្រជុំ ប្រធាននាយកដ្ឋាននោះ អាចស្នើចាត់តាំងអនុប្រធាននាយកដ្ឋានឱ្យចូលរួមជាតំណាងរបស់ខ្លួននៅក្នុងកិច្ចប្រជុំ។ សមាជិក "ក្រុមការងារជំនាញវិមជ្ឈការ និង វិសហមជ្ឈការ" នៃគណៈកម្មាធិការកំណែទំរង់ អាចស្នើសុំការអនុញ្ញាតពីប្រធានក្រុម ដើម្បីចាត់ឱ្យអ្នកឯកទេស ឬ មន្ត្រីជំនាញទទួលបន្ទុកផ្ទាល់លើកិច្ចការកំណែទំរង់និមួយៗ ចូលរួមប្រជុំក្នុងនាមជាជំនួយការ ។

ប្រការ ៦: "ក្រុមការងារជំនាញវិមជ្ឈការ និង វិសហមជ្ឈការ" មានលេខាធិការដ្ឋានមួយ ជាសេនាធិការបច្ចេកទេសរបស់ខ្លួនក្នុងការបំពេញការងារ។ សមាសភាពមុខងារ និង ភារកិច្ចលំអិតរបស់លេខាធិការដ្ឋាន "ក្រុមការងារជំនាញវិមជ្ឈការ និង វិសហមជ្ឈការ" នឹងត្រូវបានកំនត់នៅក្នុងល័ក្ខខ័ណ្ឌយោងដោយឡែក ដោយប្រធាននៃ គ.ក.ហ តាមសំណើរបស់ប្រធាន "ក្រុមការងារជំនាញវិមជ្ឈការ និង វិសហមជ្ឈការ" ។

ប្រការ ៧: "ក្រុមការងារជំនាញវិមជ្ឈការ និង វិសហមជ្ឈការ" ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំពេញការងារ និង ភារកិច្ចរបស់ខ្លួន ។

ប្រការ ៨: ប្រកាសលេខ ២២៩ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៩: ប្រកាសនេះនឹងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
គាត ឈន់

ចំលងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រុមការងារជំនាញវិមជ្ឈការ និង វិសហមជ្ឈការ
  ដូចក្នុងប្រការ ១ ដើម្បីអនុវត្ត
- កាលប្បវត្តិ / ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៤៤០ ឧរម-កឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ មេសា ឆ្នាំ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១៣៧៧/០៦ ត.វ.ក ចុះថ្ងៃទី ០៤.០៤.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន វីនសូល ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី២២.០៣.២០០៦

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន វីនសូល ហ្គាមេន (ខេមបូឌា) (WINSOL GARMENT (CAMBODIA) CO., LTD.) តំណាងដោយលោក CHEN, FU-JIANN សញ្ជាតិចិន "តៃវ៉ាន់" អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 130373845 ចុះថ្ងៃទី០៤.០៧.២០០០ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " **វីនសូល ហ្គាមេន (ខេមបូឌា) (WINSOL GARMENT (CAMBODIA))** " មានទីតាំងស្ថិតនៅ ភូមិថ្មី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឹងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន វីនសូល ហ្គាមេន (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៩ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៤៤១ ឧរថ.កឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញប្រកាសលេខ ៤០០ ឧរថកឧ.ប្រក ចុះថ្ងៃទី ២៧.០៥.២០០៣ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៣៥/០៦ គ.វ.ក ចុះថ្ងៃទី ០១.០២.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ឃែនធើរេន អ៉ីភើរ៉ល (ខេមបូឌា) ចុះថ្ងៃទី ២៨.០២.២០០៦

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ឃែនធើរេន អ៉ីភើរ៉ល (ខេមបូឌា) (CANTERAN APPAREL (CAMBODIA) CO., LTD.) តំណាងដោយ លោក YONG YUAN TAN សញ្ជាតិសិង្ហបុរី អាយុ៦៥ឆ្នាំ កាន់លិខិតឆ្លងដែនលេខ S03506190 ចុះថ្ងៃទី២០.០៦.២០០១ បង្កើតសាខារោងចក្រ "កាត់ដេរសម្លៀកបំពាក់ "ដែលមានឈ្មោះថា "ឃែនធើរេន អ៉ីភើរ៉ល (ខេមបូឌា) សាខាទី១ (CANTERAN APPAREL (CAMBODIA) BRANCH No 1)" មានទីតាំងស្ថិតនៅ ដីឡូត៍លេខ១៦៧១ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់"ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាព ផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ឃែនធើរេន អ៊ីភើរីល(ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :-
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
